# សេចក្តីថ្លែងការណ៍រួម

# របាយការណ៍ឆ្នាំ២០២៣ ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា

## ចេញផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា និងមជ្ឈមណ្ឌលសាមគ្គីភាព

ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា («អាដហុក») និងមជ្ឈមណ្ឌលសាមគ្គីភាព ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំ២០២៣ ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលផលិតដោយគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន («គម្រោង»)។ របាយការណ៍នេះលើកឡើងពិស្តារអំពីទិដ្ឋភាពនៃការអនុវត្តសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ («សេរីភាពមូលដ្ឋាន») នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ លោកអ្នកអាចទាញយករបាយការណ៍ប្រចាំឆ្នាំ២០២៣ នេះជា ភាសាខ្មែរ និង អង់គ្លេស តាមរយៈតំណទីនេះ។ លោកអ្នកក៏អាចទាញយករបាយការណ៍ចំនួនប្រាំពីរដែលចេញផ្សាយមុនៗជា ភាសាខ្មែរ និងអង់គ្លេសបានផងដែរ។

**ការវិវឌ្ឍសំខាន់ៗ ដែលត្រូវបានចងក្រងនៅក្នុងឆ្នាំ២០២៣ រួមមាន៖**

- អនុក្រឹត្យចំនួនបីដែលអាចប៉ះពាល់ដល់លទ្ធភាពរបស់ពលរដ្ឋក្នុងការអនុវត្តសេរីភាពមូលដ្ឋាននិងសិទ្ធិឯកជនភាព និងច្បាប់ដែលអនុម័តថ្មីៗដែលមានគោលបំណងប្រហាក់ប្រហែលគ្នា។
- មានការកើនឡើង១១% នៃហេតុការណ៍រឹតត្បិត និងរំលោភបំពានសេរីភាពមូលដ្ឋានបើប្រៀបធៀបនឹងឆ្នាំ២០២២។
- ការរាយការណ៍ក្នុងចំណោមថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក្នុងការរឹតត្បិតខ្លួនឯងបានថយចុះបន្តិច ប៉ុន្តែតួលេខនៅតែមានកម្រិតខ្ពស់គួរព្រួយបារម្ភ។
- ការដកហូតអាជ្ញាប័ណ្ណសារព័ត៌មានរួមមានវិទ្យុសំលេងប្រជាធិបតេយ្យ "វីអូឌី" និង
- ពលរដ្ឋកាន់តែមានជំនឿថា ពួកគេពុំមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួននៅទីសាធារណៈ។

សេរីភាពខាងសមាគម ការជួបប្រជុំ និងការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះក្នុងការធានាដល់ការអនុវត្តសិទ្ធិមនុស្សទាំងអស់ និងមានសារៈសំខាន់ខ្លាំងណាស់ដែលជួយឱ្យលទ្ធិប្រជាធិបតេយ្យដំណើរការទៅបានដោយរលូន។ សេរីភាពមូលដ្ឋាននេះជួយដល់ប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពនានា និងនាំមកនូវការវិវឌ្ឍសង្គមជាវិជ្ជមាន។ របត់នៃការរឹតត្បិត និងរំលោភបំពានលើការអនុវត្តសេរីភាពមូលដ្ឋាននៅក្នុងឆ្នាំ២០២៣ មានសញ្ញាណគួរឱ្យព្រួយបារម្ភ ខណៈប្រទេសកម្ពុជាមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលការអនុវត្តសេរីភាពមូលដ្ឋានមានសារៈសំខាន់ធានាឱ្យមានការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

របាយការណ៍ចុងក្រោយរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជានេះ បានកត់ត្រាហេតុការណ៍ចំនួន២៦២ តាមបណ្តាញផ្សព្វផ្សាយព័ត៌មាន ការរាយការណ៍ពីហេតុការណ៍មានចំនួន ៣៧១ ហេតុការណ៍ ការស្ទង់មតិជាមួយសាធារណជនចំនួន ១,០០៥ នាក់ នៅទូទាំង២៥ រាជធានីខេត្ត និងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពចំនួន ១៥៩ នាក់។ គម្រោងបានកត់ត្រាករណីនៃការរឹតត្បិតលើសេរីភាពមូលដ្ឋាននៅគ្រប់ខេត្តរាជធានី ដោយការរឹតត្បិតខ្លាំងជាងគេគឺកើតឡើងនៅរាជធានីភ្នំពេញ។

តាមរយៈការផ្តល់ទន្នីករណ៍ដែលមានប្រភពព័ត៌មានច្បាស់លាស់ អំពីស្ថានភាពនៃសេរីភាពមូលដ្ឋាននៅកម្ពុជានេះ គម្រោងសេរីភាពមូលដ្ឋានមានបំណងផ្តល់នូវមូលដ្ឋានសម្រាប់ពិចារណាផ្អែកលើព័ត៌មានដែលប្រមូលបានប្រកបដោយបរិយាបន្ន និងការពិភាក្សាច្បាស់លាស់ដើម្បីធ្វើឱ្យច្បាប់ជាតិអនុលោមជាមួយច្បាប់អន្តរជាតិ។ គម្រោងសេរីភាពមូលដ្ឋាន ស្នើឱ្យមានវិធានការក្នុងន័យស្ថាបនាឆ្ពោះទៅរកការបង្កើតលក្ខខណ្ឌចាំបាច់នានាសម្រាប់សង្គមស៊ីវិលដើម្បីឱ្យលទ្ធិប្រជាធិបតេយ្យរីកចម្រើនទៅបាន៕

**- ចប់ -**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក នី សុខា ប្រធានសមាគមអាដហុក តាមរយៈអ៊ីម៉ែល sokhany@adhoccambodia.org ឬ ទូរស័ព្ទៈ + ៨៥៥ (០) ៨៦ ៣៧៤ ៦៦៦
អ្នកស្រី ប្រាក់ ចាន់ម្លី អ្នកសម្របសម្រួលគម្រោងសេរីភាពមូលដ្ឋាន នៃ ម.ស.ម.ក តាមរយៈអ៊ីម៉ែល៖ chanmly.prak@cchrcambodia.org ឬ ទូរស័ព្ទៈ + ៨៥៥ (០) ៧៧ ៦៩១ ១៣១ ។
លោក យឹម សេរីវឌ្ឍនៈ មន្ត្រីកម្មវិធីជាន់ខ្ពស់ផ្នែកកម្មវិធីនៃមជ្ឈមណ្ឌលសាមគ្គីភាព តាមរយៈអ៊ីម៉ែល៖ vathanak@solidaritycenter.org ឬ ទូរស័ព្ទៈ + ៨៥៥ (០)៩២ ៥៥៣ ៧៧៨។